# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Apr-2016, 09:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមរូបថត ស-២១ ទៅក្នុងបញ្ជីពាក់ព័ន្ធ ដែលបានទទួលយកជាឯកសារ E3/9214

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វណ្ណល័ក្ស
លោក Calvin SAUNDERS

១. អនុលោមតាមវិធាន ៨៧(៣) និង វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាស្នើសុំថា អង្គជំនុំជម្រះសាលាដំបូង ទទួលយករូបថតពីមន្ទីរ ស-២១ ដែលបានដាក់ក្នុង **ឧបសម្ព័ន្ធ ១** ខាងក្រោម ជាផ្នែកមួយនៃឯកសារដែលមានស្រាប់ **E3/9214** ដែលបានទទួលយកក្នុងសំណុំរឿង ០០២។

២. នៅក្នុងបញ្ជីឯកសារសវនាការរបស់ខ្លួន ដែលបានដាក់នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យទទួលយកកម្រងរូបថតពីមន្ទីរ ស-២១ ថ្មីមួយ ដែលទទួលបានពី DC-Cam តាមរយៈកិច្ចស៊ើបសួរសំណុំរឿង០០២ និងការចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២ ដូចក្នុងលេខរាង ៦៦ ក្នុងឧបសម្ពន្ធ **គ**២[3]។ នៅក្នុងការដាក់ឯកសារនោះ សហព្រះរាជអាជ្ញាបានណែនាំថា DC-Cam អាចផ្តល់ឲ្យតែបញ្ជី ឬសន្ទស្សន៍នៃរូបថតថ្មីៗនៅពេលនោះតែប៉ុណ្ណោះដោយសារតែរូបថតទាំងនោះកំពុងត្រូវបានប្រើសម្រាប់ការតាំងពិពណ៌និងមិនអាចថតចម្លងបានទេ[4]។ សន្ទស្សន៍នៃរូបថតពីមន្ទីរ ស-២១ ត្រូវបានដាក់ជា ERN 00993310-66 និងត្រូវបានដាក់ជាបន្តបន្ទាប់ក្នុងសំណុំរឿងដោយអង្គជំនុំជម្រះសាលាដំបូងជាឯកសារ **E305/13.23.66** និង ត្រូវបានទទួលយកជាឯកសារ **E3/9214**។ សំណៅថតចម្លងនៃរូបថតទាំងនោះដែលរៀបរាប់ក្នុងឯកសារ **E3/9214** អាចរកបានតាមរយៈ DC-Cam ក្នុងសម្តាហ៍នេះ និងត្រូវបានភ្ជាប់ជា **ឧបសម្ពន្ធ ១** ខាងក្រោម (ERN P 01223690-01223847)។

៣. រូបថតដែលបានដាក់ជូននេះ ពាក់ព័ន្ធនឹងវគ្គសវនាការស្តីអំពីមន្ទីរសន្តិសុខ ស-២១ នៃសំណុំរឿង ០០២/០២ ហើយដែលបានបំពេញទៅតាមលក្ខណវិនិច្ឆ័យសម្រាប់ការទទួលយកភ័ស្តុតាង ស្របតាមវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង។ រូបថតទាំងនេះ គឺជាផ្នែកនៃឯកសារមួយដែលបានដាក់បញ្ចូលដោយសហព្រះរាជអាជ្ញាក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន កាលពីខែមិថុនា ឆ្នាំ២០១៤ ដែលទទួលបានការអនុម័តសម្រាប់ការទទួលដោយអង្គជំនុំជម្រះសាលាដំបូង រួចហើយ។ លើសពីការអនុវត្តតាមវិធាន៨៧(៤) គឺថារូបថតទាំងនេះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការទេ ហើយសំណៅចម្លងគេអាចទទួលបានតែពីមជ្ឈមណ្ឌល DC-Cam ប៉ុណ្ណោះ ពីសប្តាហ៍កន្លង។ រូបថតទាំងនេះក៏ជាប់ពាក់ព័ន្ធ"យ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅក្នុងសំណុំរឿង" ដែលបានទទួលយករួចហើយដោយអង្គជំនុំជម្រះ[5] ដែរ។

---

[3] **E305/13.23** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលបានធ្វើបច្ចុប្បន្នភាពតាមវិធាន៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង, ឧបសម្ពន្ធ **គ**២ – ឯកសារមិននៅក្នុងសំណុំរឿង០០២, លេខ៦៦។

[4] *ដដែលដូចខាងលើ។*

[5] **E260** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ "ចម្លើយតបទៅនឹងសំណើតាមវិធាន៨៧(៤) សុំដាក់ឯកសារថ្មីៗចូលក្នុងសំណុំរឿង, ១៨ មករា ២០១៣, កថាខណ្ឌ៥។ **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក Rob Lemkin, ២៤ កក្កដា ២០១៣, កថាខណ្ឌ១០។

៤. ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យដាក់រូបទាំងនេះទៅក្នុង **ឧបសម្ព័ន្ធ ១** ដែលត្រូវបញ្ចូលទៅក្នុងឯកសារ E3/9214 ដែលមានស្រាប់នៃសំណុំរឿង០០២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |